ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:......1031....PEAC អ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ០៧ ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី

ឈ្នួលពលកម្មតម្លើង Package Type Transformer( PTT ) ថ្មីត្រង់ស្វូមានអនុភាព 1000kVA ចំនួន 01 គ្រឿង ដើម្បីកាត់បន្ថយបន្ទុកនៅប.ត 370 នៅសង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និង ឈ្នួលពលកម្មប្តូរខ្សែកាប MV,ABC: 3x 150mm$^2$+1x150mm$^2$ ដែលខូចគុណភាពចន្លោះ DS និង ប្រព័ន្ធនាឡិការស្ទង់របស់ប.ត 771 នៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា: អគ្គិសនីកម្ពុជា នឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការអញ្ជើញចូលរួមពិគ្រោះថ្លៃឈ្នួលពលកម្មតម្លើង Package Type Transformer( PTT ) ថ្មីត្រង់ស្វូមានអនុភាព1000 kVA ចំនួន 01 គ្រឿង ដើម្បីកាត់បន្ថយបន្ទុកនៅ ប.ត 370 នៅសង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និង ឈ្នួលពលកម្មប្តូរខ្សែកាប MV, ABC: 3x150mm$^2$+1x150mm$^2$ ដែលខូចគុណភាពចន្លោះ DS និង ប្រព័ន្ធនាឡិការស្ទង់ របស់ប.ត 771 នៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជូននាយកដ្ឋានអាជីវកម្មចែកចាយ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋាន: ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទង: 023 67 66 007 និង Website: www.edc.com.kh ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោង ១១ : 00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ វេលាម៉ោង ១៥:៣០ នាទី ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័តមានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ចម្លងជូន:
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ